# សុជាតជាតក



កាលព្រះសាស្តា កាលស្តេចគង់នៅវត្តជេតពន ប្រារព្ធនាងសុជាតា ជាធីតារបស់ធនញ្ជយសេដ្ឋី ហើយជាប្អូនស្រីរបស់នាងវិសាខា និងជាកូនប្រសារបស់អនាថបិណ្ឌិកសេដ្ឋី បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **ន ហិ វណ្ណេន សម្បន្នា** ដូច្នេះជាដើម ។

មានសេចក្តីតំណាលថា ផ្ទះអនាថបិណ្ឌិកសេដ្ឋី តាំងពីបាននាងសុជាតាចូលទៅនៅ (ឈ្មោះថា) នាងបានបំពេញដោយយសដ៏ធំ តែនាងមានសេចក្តីចចេសរឹងត្អឹង ប្រកាន់មានះអាងថា យើងជាធីតារបស់មហាត្រកូល ដូច្នេះទើបច្រើនទៅដោយសេចក្តីក្រេវក្រោធ ខឹងសម្បាកាច ផ្តាស សំដីអាក្រក់ មិនធ្វើវត្តប្រតិបត្តិគោរពមាតាបិតាក្មេក និងស្វាមីរបស់ខ្លួន ចេះតែដេរប្រទេចគំហកកំហែងវាយដំទះតប់ជនអ្នកនៅក្នុងផ្ទះ ។

ថ្ងៃមួយ ព្រះសាស្តាមានភិក្ខុ ៥០០ ជាបរិវារ យាងទៅកាន់ផ្ទះអានាថបិណ្ឌិកសេដ្ឋី ហើយព្រះអង្គប្រថាប់ ។ មហាសេដ្ឋីអង្គុយស្តាប់ធម៌ជិតព្រះមានព្រះភាគ ក្នុងខណៈនោះ នាងសុជាតាឈ្លោះប្រកែកជាមួយពួកទាសកម្មករ ។ ព្រះសាស្តាក៏បញ្ឈប់ធម្មកថា ហើយត្រាស់សួរថា នោះ

ជាសំឡេងអ្វី ? សេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នោះជាកូនប្រសារបស់ត្រកូល នាងមិនមានសេចក្តីគោរពកោតក្រែង មិនធ្វើវត្តចំពោះឪពុកម្តាយក្មេកនិងប្តីរបស់ខ្លួនឡើយ ជាស្ត្រីមិនមានសទ្ធា មិនជ្រះថ្លា ចេះតែឈ្លោះទាស់ទែងរាល់ព្រឹកល្ងាច ។ ព្រះមានព្រះភាគត្រាស់ថា បើយ៉ាងនោះ អ្នកចូរឲ្យគេហៅនាងមក ។ នាងសុជាតាក៏មកថ្វាយបង្គំ ហើយអង្គុយក្នុងទីដ៏សមគួរ ។

លំដាប់នោះ ព្រះសាស្តាត្រាស់សួរនាងថា នែនាងសុជាតា ភរិយារបស់បុរស មាន ៧ ពួក តើនាងជាភរិយារបស់បុរស ដូចម្តេច ? នាងទូលថា ខ្ញុំម្ចាស់មិនយល់សេចក្តី ដែលព្រះអង្គត្រាស់សួរដូច្នេះទេ សូមទ្រង់សម្តែងឲ្យពិស្តារផង ។ ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ នាងចូរស្តាប់ចុះ ហើយទ្រង់សម្តែងគាថាទាំងនេះថា

បទុដ្ឋចិត្តា អហិតានុកម្បិនី, អញ្ញេសុ រត្តា អតិមញ្ញតេ បតឹ,
ធនេន កីតស្ស វធាយ ឧស្សុកា; យា ឯវរូបា បុរិសស្ស ភរិយា,
**វធកា ច ភរិយា**តិ ច សា បវុច្ចតិ។

ភរិយាដែលស្វាមីលោះមកដោយទ្រព្យ ស្ត្រីមានចិត្តប្រទូស្ត (នឹងស្វាមី) មានសេចក្តីមិនអនុគ្រោះនូវប្រយោជន៍ ជាអ្នកត្រេកត្រអាលក្នុងបុរសដទៃ មើលងាយប្តី ខ្វល់ខ្វាយដើម្បីសម្លាប់ (ប្តី) ស្ត្រីណា ជាភរិយានៃបុរស មានសភាពដូច្នេះ ស្ត្រីនោះ ហៅថា **វធកាភរិយា** (ភរិយាទុកស្មើពេជ្ឈឃាត) ។

យំ ឥត្ថិយា វិន្ទតិ សាមិកោ ធនំ, សិប្បំ វណិជ្ជញ្ច កសិំ អធិដ្ឋហំ,
អប្បម្បិ តស្ស អបហាតុមិច្ឆតិ; យា ឯវរូបា បុរិសស្ស ភរិយា,
ចោរី ច **ភរិយា**តិ ច សា បវុច្ចតិ។

ស្វាមីនៃស្ត្រីបាននូវទ្រព្យណាហើយតម្កល់ទុក ដើម្បីធ្វើនូវសិល្បៈក្តី នូវជំនួញក្តី នូវកសិកម្មក្តី ស្ត្រីនោះ ប្រាថ្នាដើម្បីលួចកិបយកនូវទ្រព្យ សូម្បីបន្តិចបន្តួចអំពីទ្រព្យនោះ ស្ត្រីណាជាភរិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះ ហៅថា **ចោរីភរិយា** (ភរិយាជាចោរ) ។

អកម្មកាមា អលសា មហគ្ឃសា, ផរុសា ច ចណ្ឌី ច ទុរុត្តវាទិនី,

ឧដ្ឋាយិកា អតិកុយ្ហ វត្តតិ; យា ឯវរូបា បុរិសស្ស ភរិយា,
**អយ្យា ច ភរិយាតិ** ច សា បវុច្ចតិ។

*ស្ត្រីមិនមានសេចក្តីប្រាថ្នានឹងធ្វើនូវការងារ ជាអ្នកខ្ជិលច្រអូស ស៊ីច្រើន រឹងរូស កាចពោលនូវពាក្យអាក្រក់ ប្រព្រឹត្តគ្របសង្កត់នូវស្វាមី ដែលមានព្យាយាម ប្រឹងប្រែង ស្ត្រីណាជាភរិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះ ហៅថា **អយ្យាភរិយា** (ភរិយាស្មើចៅហ្វាយនាយ) ។*

យា សព្វទា ហោតិ ហិតានុកម្បិនី, មាតាវ បុត្តំ អនុរក្ខតេ បតឹ,
តតោ ធនំ សម្ភតមស្ស រក្ខតិ; យា ឯវរូបា បុរិសស្ស ភរិយា,
មាតា ច **ភរិយាតិ** ច សា បវុច្ចតិ។

*ស្ត្រីណា មានសេចក្តីអនុគ្រោះនូវប្រយោជន៍សព្វ ៗ កាលចេះរក្សាប្តី ដូចជាមាតារក្សាកូន ទាំងរក្សានូវទ្រព្យដែលស្វាមីនោះ បានមកអំពីទីនោះ ៗ ស្ត្រីណាជា ភរិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះ ហៅថា **មាតាភរិយា** (ភរិយាទុកស្មើម្តាយ) ។*

យថាបិ ជេដ្ឋា ភគិនី កនិដ្ឋកា, សគារវា ហោតិ សកម្ហិ សាមិកេ,
ហិរីមនា ភត្តុ វសានុវត្តិនី; យា ឯវរូបា បុរិសស្ស ភរិយា,
**ភគិនី ច ភរិយាតិ** ច សា បវុច្ចតិ។

*ស្ត្រីមានសេចក្តីគោរព ក្នុងស្វាមីរបស់ខ្លួន ដូចប្អូនស្រីគោរពបងប្រុស មានសេចក្តីអៀនខ្មាស ប្រព្រឹត្តទៅតាមអំណាចនៃភស្តា ស្ត្រីណា ជាភរិយានៃបុរសមានសភាពដូច្នេះ ស្ត្រីនោះ ហៅថា **ភគិនីភរិយា** (ភរិយាទុកដូចជាប្អូនស្រី) ។*

យាចីធ ទិស្វាន បតឹ បមោទតិ, សខី សខារំវ ចិរស្សមាគតំ,
កោលេយ្យកា សីលវតី បតិព្វតា; យា ឯវរូបា បុរិសស្ស ភរិយា,
**សខី ច ភរិយាតិ** ច សា បវុច្ចតិ។

*ស្ត្រីណា ក្នុងលោកនេះ បានឃើញនូវប្តីហើយ ក៏រីករាយ ដូចជាសម្លាញ់បានឃើញសម្លាញ់ ដែលមកអស់កាលយូរ ស្ត្រីនោះបរិបូណ៌ដោយត្រកូល មានសីលធម៌ ជាស្ត្រីមាន*

*វត្តប្រតិបត្តិក្នុងប្តី ស្ត្រីណា ជាភរិយានៃបុរស មានសភាពដូច្នេះ ស្ត្រីនោះ ហៅថា* ***សខីភរិយា*** *(ភរិយាទុកដូចជាសម្លាញ់)* ។

អក្កុទ្ធសន្តា វធទណ្ឌតជ្ជិតា, អទុដ្ឋចិត្តា បតិនោ តិតិក្ខតិ,
អក្កោធនា ភត្តុ វសានុវត្តិនី; យា ឯវរូបា បុរិសស្ស ភរិយា,
**ទាសី ច ភរិយា**តិ ច សា បវុច្ចតិ។

*ស្ត្រីដែលស្វាមីជេរ វាយ គំរាមដោយដំបង មិនមានចិត្តប្រទូស្តវិញ ចេះអត់សង្កត់ដល់ប្តី មិនក្រោធ ប្រព្រឹត្តទៅតាមអំណាចនៃភស្តា ស្ត្រីណាជាភរិយានៃបុរស មានសភាពដូច្នេះ ស្ត្រីនោះ ហៅថា* ***ទាសីភរិយា*** *(ភរិយាទុកដូចជាទាសី)* ។

*(សុត្តន្តបិដក អង្គុត្តរនិកាយ សត្តកនិបាត អព្យាកតវគ្គ ភរិយាសូត្រ បិដកលេខ ៤៧ ទំព័រ ១៦៩)*

*នៃនាងសុជាតា ភរិយាមាន ៧ ពួកនេះ ។ បណ្តាភរិយាទាំង ៧ នោះ ភរិយា ៣ ពួក គឺ* **វធកសមា** *(ភរិយាទុកស្មើអ្នកសម្លាប់)* ១ **ចោរសមា** *(ភរិយាទុកស្មើចោរ)* ១ **អយ្យសមា** *(ភរិយាទុកស្មើម្ចាស់)* ១ *(ស្លាប់ទៅ) រមែងកើតនៅក្នុងនរក ឯភរិយា ៤ ពួកក្រៅនេះ (ស្លាប់ទៅ) នឹងទៅកើតក្នុងទេវលោកជាន់និម្មានរតី* ។

*(ព្រះពុទ្ធត្រាស់ទៀតថា)*

យាចីធ ភរិយា វធកាតិ វុច្ចតិ, ចោរីតិ អយ្យាតិ ច យា បវុច្ចតិ;
ទុស្សីលរូបា ផរុសា អនាទរា, កាយស្ស ភេទា និរយំ វជន្តិ តា។

*ភរិយាណា ក្នុងលោកនេះ ដែលហៅថា វធកាក្តី ហៅថា ចោរីក្តី ហៅថាអយ្យាក្តី ភរិយាទាំងនោះ មានសភាពជាស្ត្រីទ្រុស្តសីល រឹងរូស មិនមានសេចក្តីគោរព លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកាន់នរក* ។

យាចីធ មាតា ភគិនី សខីតិ ច, ទាសីតិ ភរិយាតិ ច យា បវុច្ចតិ;
សីលេ ឋិតត្តា ចិររត្តសំវុតា, កាយស្ស ភេទា សុគតឹ វជន្តិ តា។

*ភរិយាណាក្នុងលោកនេះ ដែលហៅថាមាតាក្តី ភគិនីក្តី សខីក្តី ទាសីក្តី ភរិយាទាំងនោះ ជាស្ត្រីសង្រួមអស់កាលជាយូរអង្វែង ព្រោះតាំងនៅក្នុងសីលធម៌ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកាន់សុគតិ* ។

*(សុត្តន្តបិដក អង្គុត្តរនិកាយ សត្តកនិបាត អព្យាកតវគ្គ ភរិយាសូត្រ បិដកលេខ ៤៧ ទំព័រ ១៧២)*

កាលព្រះសាស្តាសម្តែងភរិយា ៧ ពួកនេះហើយ នាងសុជាតាបានតាំងនៅក្នុងសោតាបត្តិផល ។ ព្រះពុទ្ធត្រាស់សួរថា នែនាងសុជាតា បណ្តាភរិយាទាំង ៧ ពួកនេះ តើនាងជាភរិយាបែបណា ? នាងសុជាតាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់ជាទាសីភរិយា (ភរិយាទុកស្មើខ្ញុំស្រី) រួចនាងថ្វាយបង្គំសូមខមាទោសព្រះតថាគត ។ ព្រះសាស្តាទូន្មាននាងសុជាតាដែលជា**យរសុណិសា** (កូនប្រសាស្រីក្នុងផ្ទះ) ដោយឱវាទតែមួយ កាលសម្រេចភត្តកិច្ចហើយ ទ្រង់យាងទៅកាន់វត្តជេតវនវិញ កាលភិក្ខុសង្ឃសម្តែងកិច្ចវត្តថ្វាយស្រេចហើយ ទ្រង់យាងចូលក្នុង**គន្ធកុដិ** ។ ភិក្ខុទាំងឡាយញុំាំងគុណកថារបស់ព្រះសាស្តាឲ្យតាំងឡើងក្នុងធម្មសភាថា ម្នាលអាវុសោ ព្រះសាស្តាទូន្មាននាង**សុជាតាយរសុណិសា** ដោយឱវាទតែម្តង នាងក៏បានតាំងនៅក្នុងសោតាបត្តិផល ។ ព្រះសាស្តាយាងមក ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នានិយាយរឿងអ្វី ? កាលពួកភិក្ខុទូលថា ដោយរឿងនេះ ទើបព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន នាងសុជាតាក៏តថាគតធ្លាប់ទូន្មានបានដោយឱវាទតែម្តងដូចគ្នាដែរ ហើយទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងផ្ទៃអគ្គមហេសីរបស់ស្តេចអង្គនោះ លុះចម្រើនវ័យធំហើយ បានទៅរៀនសិល្បសាស្ត្រទាំងពួងនៅឯ**នគរតក្កសិលា** អំណឹះអត់អំពីព្រះបិតាទៅ ក៏បានសោយរាជ្យប្រកបដោយធម៌ ។ ចំណែកព្រះមាតារបស់ព្រះអង្គ ជាស្ត្រីគ្រេវគ្រោធ កាចរឹងរូស គិតតែជេរប្រទេចផ្តាសា ។ ព្រះពោធិសត្វចង់ថ្វាយឱវាទដល់ព្រះមាតាដែរ តែគិតថា មិនគួរនិយាយដោយមិនមានរឿងជាឧទាហរណ៍ឡើយ ដូច្នេះទើបសម្លឹងមើល រកសេចក្តីឧបមាណាមួយ ដើម្បីជាការទូន្មានព្រះនាង ។

ថ្ងៃមួយ ស្តេចយាងទៅក្រសាលឧទ្យាន សូម្បីព្រះមាតាក៏យាងទៅជាមួយនឹងបុត្រ ។ លុះដល់ពាក់កណ្តាលផ្លូវ មានសត្វត្រដេវរិចមួយស្រែកយំ ពួកបុរសរបស់ព្រះពោធិសត្វឮសំឡេងនោះហើយ នាំគ្នាបិទត្រចៀក ស្រែកឡើងថា នែវ៉ើយអាសត្វសំដីកំណាច សំដីអាក្រក់ ឯងកុំស្រែកយំ ។ កាលព្រះពោធិសត្វមានពួកស្រីរបាំហែហម ទ្រង់យាងទៅឧទ្យានជាមួយព្រះមាតា មានសត្វតាវៅមួយសម្ងំទំលើដើមរាំងដែលមានផ្ការីកស្គុះស្គាយ វាយំដោយសូរសៀងដ៏ពីរោះ ។ មហាជនជក់ចិត្តដោយសំឡេងនោះ ហើយប្រណម្យអញ្ជលី ស្រែកអង្វរថា នែបក្សីមានសំដី

ផ្អែមល្ហែមជាទីស្រឡាញ់ មានសំដីទន់ភ្លន់ អ្នកចូរបង្អុរសូរសព្ទមកទៀតចុះ រួចនាំគ្នាងើយកឡើង មានត្រចៀកផ្ទៀងស្តាប់ ឈរសម្លឹងរកមើល ។

លំដាប់នោះ ព្រះមហាសត្វឃើញហេតុទាំងពីរនេះ ហើយគិតថា ឥឡូវនេះ អញនឹងអាចញុំាងព្រះមាតាឲ្យយល់បាន ទើបទូលថា បពិត្រព្រះមាតា មហាជនឮសំឡេងត្រដេវរិច នៅកណ្តាលផ្លូវ ក៏នាំគ្នាបិទត្រចៀក ស្រែកឃាត់ថា កុំស្រែក កុំស្រែក ឈ្មោះថា **ផរុសវាចា** សំដីអាក្រក់ រមែងមិនជាទីគាប់ចិត្តដល់អ្នកណាមួយឡើយ ហើយពោលគាថាទាំងនេះថា

ន ហិ វណ្ណេន សម្បន្នា, មញ្ជុកា បិយទស្សនា;
ខរវាចា បិយា ហោន្តិ, អស្មឹ លោកេ បរម្ហិ ច។

ពួកជនប្រកបដោយសម្បុរ មានសំឡេងពីរោះ មានរូបជាទីស្រឡាញ់ គួររមិលមើល តែជាអ្នកមានវាចារឹងរូស មិនជាទីស្រឡាញ់របស់អ្នកផង ក្នុងលោកនេះនិងលោកខាងមុខទេ ។

ននុ បស្សសិមំ កាឡឹ, ទុព្ពណ្ណំ តិលកាហតំ;
កោកិលំ សណ្ហភាណេន, ពហូនំ បាណិនំ បិយំ។

ព្រះមាតា ឃើញមេតាវៅខ្មៅនេះ ដែលមានសម្បុរអាក្រក់ ដេរដាសដោយពណ៌ពព្រុះអុចៗ តែជាជាទីស្រឡាញ់ របស់សត្វច្រើន ដោយសារវាចាពីរោះឬទេ ។

តស្មា សខិលវាចស្ស, មន្តភាណី អនុទ្ធតោ;
អត្ថំ ធម្មញ្ច ទីបេតិ, មធុរំ តស្ស ភាសិតំ។

ព្រោះហេតុនោះ បុគ្គលគប្បីជាអ្នកមានវាចាល្អិតល្អ ជាអ្នកពោលពាក្យលៃតាមប្រាជ្ញា មិនមានចិត្តរាយមាយ រមែងសំដែងនូវអត្ថនិងធម៌ ភាសិតរបស់បុគ្គលនោះ ទើបឈ្មោះថាពីរោះ ។

ព្រះពោធិសត្វសម្តែងធម៌ថ្វាយព្រះមាតា ដោយគាថាទាំង ៣ នេះ យ៉ាងនេះហើយ ញុំាងព្រះនាងឲ្យយល់, ចាប់ពីពេលនោះមក ព្រះនាងក៏បរិបូណ៌ដោយអាចារៈ ។ ចំណែកព្រះពោធិសត្វញុំាងព្រះមាតាឲ្យលែងសេពគប់ខុស ដោយឱវាទតែម្តងហើយ ក៏ទៅតាមយថាកម្ម ។

ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា

**តទា ពារាណសិរញ្ញោ មាតា សុជាតា អហោសិ** *មាតារបស់ព្រះរាជាពារាណសី*

*ក្នុងកាលនោះ បានមកជានាងសុជាតា*

**រាជា បន អហមេវ អហោសឹ** *ចំណែកព្រះរាជា គឺ តថាគតនេះឯង ។*

*(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តិកនិបាត បទុមវគ្គ  បិដកលេខ ៥៨ ទំព័រ ១៥៥)*

*ថ្ងៃសៅរ៍ ១១ កើត ខែអស្សុជ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ២០ ខែ តុលា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*